


# បណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភកម្ពុជា

Scaling Up NUTRITION

Business Network

ENGAGE • INSPIRE • INVEST

## តើបណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ(SBN) ជាអ្វី?

ចលនាបង្កើនអាហារូបត្ថម្ភគឺជាកិច្ចខិតខំប្រឹងប្រែងពហុភាគី ថ្នាក់ពិភពលោកដើម្បីលុបបំបាត់បញ្ហាអាហារូបត្ថម្ភ។ **បណ្តាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភ** គឺជាបណ្តាញមួយក្នុងចំណោមបណ្តាញធំៗទាំងបួន ដែលមានគោលបំណងប្រើប្រាស់នូវជំនាញឯកទេស សម្ថភាពគ្រប់ដណ្តប់ និងឥទ្ធិពលទីផ្សារពីវិស័យឯកជនដើម្បីលើកកម្ពស់អាហារូបត្ថម្ភប្រកបដោយចីរភាព។ នៅប្រទេសកម្ពុជា SBN ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការនៅក្នុងខែកក្កដា ឆ្នាំ ២០២១ ដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.) និងកម្មវិធីស្បៀងអាហារពិភពលោក។ គោលដៅយុទ្ធសាស្ត្រទាំង ៥ របស់ SBN មានបង្ហាញនៅខាងស្តាំ។

**សសរស្តម្ភយុទ្ធសាស្ត្រ**

- កសាងកេរ្តិ៍ឈ្មោះ SBN កម្ពុជាឱបានរឹងមាំ មានសមាជិកដែលសកម្ម ពេញចិត្ត និងផ្តល់ការគាំទ្រ រួមបញ្ចូលសមាជិកពីអាជីវកម្មជាសហគ្រាសធុនតូច និងមធ្យម និងអាជីវកម្មដែលមានស្ត្រីជាអ្នកដឹកនាំ
- បង្កើនតម្រូវការអាហារដែលសម្បូរជីវជាតិ និងការយល់ដឹងពីអាហារសុខភាព និងការអនុវត្តដើម្បីលើកកម្ពស់អាហារូបត្ថម្ភ
- បង្កើនការផ្គត់ផ្គង់ផលិតផលអាហារដែលសម្បូរជីវជាតិ និងផលិតផលអាហារបញ្ចូលមីក្រូសារជាតិ
- ពង្រឹងបរិយាកាសអំណោយផល ដើម្បីលើកកម្ពស់អាហារូបត្ថម្ភតាមរយៈធ្វើឱ្យប្រសើរឡើងនូវស្តង់ដារ បទប្បញ្ញត្តិ ច្បាប់ និងគោលនយោបាយនានា
- លើកកម្ពស់សុខភាព និង អាហារូបត្ថម្ភនៅតាមសហគមន៍ និងកន្លែងការងារតាមរយៈការអនុវត្តកម្មវិធីអាហារូបត្ថម្ភសម្រាប់កម្លាំងការងារ និងការទទួលបានអាហារដែលសម្បូរជីវជាតិ មានសុវត្ថិភាព និងតម្លៃសមរម្យ

## តើអ្នកណាខ្លះអាចចូលជាសមាជិក?

វិស័យឯកជនដែលធ្វើការពាក់ព័ន្ធ និងមិនពាក់ព័ន្ធនឹងស្បៀងអាហារ សកលវិទ្យាល័យនិងស្ថាប័នស្រាវជ្រាវ សមាគមធុរកិច្ច សភាពាណិជកម្ម ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នផ្សេងៗអាចចូលរួមជាសមាជិកបាន

### សមាជិកនៃបណ្តាញធុរកិច្ច នៃចលនាបង្កើនអាហារូបត្ថម្ភ

- ផលិតកម្ម និង ការកែច្នៃស្បៀង
- កសិកម្ម
- លក់រាយ
- ហិរញ្ញវត្ថុ
- ដឹកជញ្ជូន និងចែកចាយ
- សំណង់
- សេវាវិជ្ជាជីវៈ
- បណ្តាញទូរស័ព្ទចល័ត និងគមនាគមន៍
- ថាមពល សេវាសាធារណៈ និងរ៉ែ
- រាជរដ្ឋាភិបាល
- UN
- អ្នកផ្តល់ជំនួយ
- អង្គការសង្គមស៊ីវិល
- សមាគមធុរកិច្ច
- ការស្រាវជ្រាវ និងការអប់រំ
- ការថែទាំសុខភាព
- សហគមន៍អាហារូបត្ថម្ភ

## ហេតុអ្វីអ្នកគួរចូលរួមជាសមាជិករបស់ SBN ?

អត្ថប្រយោជន៍ពីការចូលជាសមាជិក SBN រួមមាន៖

- **ឱកាសចងក្រងបណ្តាញ និងចាប់ដៃគូ**ជាមួយក្រុមហ៊ុនដទៃទៀត អង្គការសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុ អ្នកផ្តល់ជំនួយ ដែលមានចំណាប់អារម្មណ៍ចំពោះវិស័យអាហារូបត្ថម្ភ និងការពង្រីកទីផ្សារអាហារូបត្ថម្ភ
- **ទទួលបានការគាំទ្រ**សម្រាប់ការរៀបចំគោលនយោបាយស្តីពីអាហារូបត្ថម្ភនៅកន្លែងការងារ និងឱកាសទទួលបាននូវវិធីសាស្ត្រអនុវត្តល្អ ដំបូន្មាន និងឧបករណ៍នានាពីថ្នាក់សកល និងថ្នាក់ជាតិ
- **ទទួលបានដំបូន្មាន ការណែនាំ និងការបណ្តុះបណ្តាល** តាមរយៈសិក្ខាសាលា និងព្រឹត្តិការណ៍នានា ដើម្បីបង្កើនការចូលរួមជាលក្ខណៈពាណិជ្ជកម្មរបស់ក្រុមហ៊ុននៅក្នុងវិស័យអាហារូបត្ថម្ភ
- **ទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីឧស្សាហកម្មអាហារ និងការផ្លាស់ប្តូរគោលនយោបាយពាក់ព័ន្ធ** ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តនៅក្នុងការធ្វើអាជីវកម្ម
- ឱកាសក្នុងការ**ចូលរួមនៅក្នុងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗ**
- ឱកាសក្នុងការ**បង្កើតតម្រូវការទីផ្សារ និងពង្រីកមូលដ្ឋានអតិថិជន**សម្រាប់អាហារ និងភេសជ្ជៈដែលសម្បូរជីវជាតិចម្រុះ
- **បង្ហាញពីការរួមចំណែករបស់អាជីវកម្ម**អ្នកក្នុងការលើកកម្ពស់អាហារូបត្ថម្ភនៅកម្រិតជាតិ និងពិភពលោក។
- **អនុវត្តកម្មវិធីទំនួលខុសត្រូវសង្គមសាជីវកម្ម** (CSR) របស់ក្រុមហ៊ុនអ្នកដើម្បីលើកកម្ពស់អាហារូបត្ថម្ភនៅក្នុងសហគមន៍។

**... និងលើសពីនេះ!**

## ការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់អាហារូបត្ថម្ភ

ដើម្បីក្លាយជាសមាជិកភាពរបស់ SBN យើងស្នើឱ្យអ្នកកំណត់គោលដៅសាជីវកម្មយ៉ាងតិចចំនួនមួយដែលនឹងរួមចំណែកដល់ការលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា។ ឧទាហរណ៍នៃគោលដៅសាជីវកម្មអាចរួមបញ្ចូល៖

- ការបង្កើនការជ្រៀតចូលទីផ្សារនៃផលិតផលអាហារដែលសម្បូរជីវជាតិ ដើម្បីឱ្យអ្នកប្រើប្រាស់កាន់តែច្រើនអាចរកទិញផលិតផលទាំងនោះបាន។
- បង្កើត ឬអនុវត្តស្តង់ដារគុណភាព និងសុវត្ថិភាពអាហារ
- វិនិយោគ ច្នៃបង្កើតផលិតផលអាហារសម្បូរជីវជាតិថ្មីៗ និងបង្កើតនិងធ្វើយុទ្ធនាការទីផ្សារដែលពាក់ព័ន្ធ
- អនុវត្តកម្មវិធីអាហារូបត្ថម្ភនៅកន្លែងការងារចំនួនមួយ ឬច្រើនដើម្បីលើកកម្ពស់ផលិតភាពការងារ និងកាត់បន្ថយអវត្តមានបុគ្គលិកដោយសារជំងឺ
- ផ្តល់ការបណ្តុះបណ្តាល ឬធ្វើការវិនិយោគលើផលិតផលកសិកម្មដើម្បីលើកទឹកចិត្តក្នុងការធ្វើពិពិធកម្មផលិតផលកសិកម្ម និងកាត់បន្ថយហានិភ័យសាជីវកម្ម

### គោលការណ៍អនុវត្តន៍

សមាជិក SBN ប្តេជ្ញាប្រតិបត្តិទៅតាមគោលការណ៍អនុវត្តន៍ជាមូលដ្ឋានមួយចំនួន យល់ព្រមលើការធ្វើទីផ្សារផលិតផលរបស់ខ្លួនស្របទៅតាមក្របខ័ណ្ឌ បទប្បញ្ញត្តិជាតិដែលមាន។ គាំទ្រដល់ និងចូលរួមយ៉ាងសកម្មភាពជាមួយ SBN កម្ពុជាដើម្បីលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ហាក់ សុខជា**
អ្នកសម្របសម្រួល SBN កម្ពុជា
T: +855 99 333 683
E: sokchea.hak@wfp.org

**ឯ.ឧ. សុខ ស៊ីឡូ**
អគ្គលេខាធិការ ក.ក.ជ.
E: soksilo@gmail.com


Scaling Up NUTRITION Business Network ENGAGE • INSPIRE • INVEST

WFP World Food Programme

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (ក.ក.ជ.)